# ដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត

អង្គការស្អាតកម្ពុជា ជាអង្គការគ្រិស្តបរិស័ទក្នុងស្រុកមួយ ដែលបាននិងកំពុងអនុវត្តគម្រោងក្រោមគោល បំណងទឹកស្អាត និង អនាម័យ (WASH)។ បេសកកម្មគឺ ដើម្បីលើកកំពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាសហគមន៍ គោលដៅដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។ ការងារទាំងអស់ត្រូវបានធ្វើឡើងដោយសហការជាមួយ ថ្នាក់ដឹកនាំ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អង្គការស្អាតកម្ពុជាបច្ចុប្បន្ន កំពុងអនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តចំនួន ១១ ដូចជា ខេត្តបាត់ដំបង ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ សៀមរាប ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ និងរតនគិរី។

យើងខ្ញុំត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន០១នាក់សម្រាប់មុខតំណែងជា **អ្នកស្ម័គ្រចិត្តផ្នែកបច្ចេកទេសដំឡើងចម្រោះទឹក** ដែលមានទីតាំងនៅ **ភូមិចុងព្រែក សង្កាត់ស្វាយ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។**

## ១. ភារកិច្ចទទួលខុសត្រូវក្នុងមុខតំណែង ៖

- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹក អោយបានត្រឹមត្រូវ តាមបទដ្ឋានដោយមានការចូលរួមពីគ្រួសារដែលទទួលផល។
- ជួយក្នុងការបង្រៀនដល់គ្រួសារដែលទទួលផល និងអ្នកស្ម័គ្រចិត្តភូមិ អំពីការដំឡើងចម្រោះទឹក។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសដំឡើងចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹក និងការបង្រៀន ដល់គ្រួសារដែលទទួលផល អោយយល់ពីគុណភាពរបស់ចម្រោះទឹក។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹកនិងពន្យល់ដល់គ្រួសារ ដែលទទួលផលអំពីដំណើរការនៃការថែរក្សាចម្រោះទឹកអោយបានត្រឹមត្រូវ និងបំផុសស្មារតីម្ចាស់ការ។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹកផ្នែកកិច្ចការរដ្ឋបាល រៀបចំកត់ត្រា ចំនួនចម្រោះទឹកដែលដំឡើងហើយ និងបញ្ចូលទៅក្នុងប្រព័ន្ធ **Iform Builder** ។
- ជួយរៀបចំ និងផ្តល់សម្ភារៈសំខាន់ៗ ដល់អ្នកស្ម័គ្រចិត្តភូមិសម្រាប់ការដំឡើងចម្រោះទឹក។
- ទទួលខុសត្រូវ និងសម្របសម្រួលលើការដំឡើងចម្រោះទឹកថ្មី។

## ២. លក្ខខណ្ឌជ្រើសរើស ៖

- បញ្ចប់ថ្នាក់វិទ្យាល័យ។
- មានបទពិសោធន៍ក្នុងការធ្វើការងារសហគមន៍ ឬសំណង់ផ្សេងៗ។
- ប្រកាន់ខ្ជាប់នូវតម្លៃ និងបេសកកម្មរបស់អង្គការស្អាតកម្ពុជា។
- មានក្រមសិលធម៌ការងារជាអាជីព។
- មានបំណងចង់ធ្វើការងារសហគមន៍។
- មានម៉ូតូផ្ទាល់ខ្លួន និងមានឆន្ទៈក្នុងការជិះម៉ូតូតាមសហគមន៍។

ចំពោះបេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ជាមួយមុខតំណែងនេះ សូមមកទទួលយកពាក្យសុំធ្វើការងារនៅការិយាល័យ **ខេត្តស្វាយរៀង** ឬអាចទាញយកពាក្យសុំបម្រើការងារជាភាសា ខ្មែរ ឬ អង់គ្លេស ទៅបំពេញហើយបញ្ជូនមកវិញដោយភ្ជាប់ជាមួយប្រវត្តិរូបសង្ខេប (CV & Cover Letter) រួចបញ្ជូនមកកាន់ការិយាល័យ **ខេត្តបាត់ដំបង** តាមរយៈអាសយដ្ឋានខាងលើ ឬទំនាក់ទំនងទូរស័ព្ទលេខ: (៨៨៥)-៣៨៤០១៦៤, E-mail: hr@clearcambodia.org, Website: www.clearcambodia.org.

***សំគាល់៖*** សូមភ្ជាប់មកជាមួយនូវឯកសារថតចំលងអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ និង ឯកសារពាក់ព័ន្ធ ផ្សេងទៀត និងរូបថត ៤X៦ ចំនួន ២សន្លឹក។

បន្ទាប់ពីពិនិត្យលើសំណុំបែបបទសុំបំរើការងារអ្នកជាប់បញ្ជីសម្រាំង និងត្រូវបានធ្វើការទំនាក់ទំនង ដើម្បីធ្វើការសម្ភាសន៍។

**ថ្ងៃផុតកំណត់ទទួលពាក្យនៅ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៦ ។**